វាជាការគួរឱ្យចាប់អារម្មណ៍ដែលត្រូវកត់សំគាល់ថា សូម្បីតែទីលំនៅរបស់អ្នកឆ្លើយសំណួរក៏មានឥទ្ធិពលទៅលើទស្សនៈរបស់ពួកគាត់ផងដែរ ។ ប្រជាពលរដ្ឋនៅខេត្តផ្សេងៗ មានការរំពឹងទុក និងកង្វល់ខុសៗគ្នា ។ អ្នកផ្តល់ការសម្ភាសន៍នៅតំបន់ដាច់ស្រយាល ទំនងជាចង់ឱ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពូលៗ ខុសពីអ្នកផ្តល់ការសម្ភាសន៍នៅតំបន់ទីប្រជុំជន ចង់ឱ្យមានការកាត់ទោសទាំងមេដឹកនាំកំពូលៗរហូតដល់កំរិតទាប ។ ប៉ុន្តែ ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាលចំនួន ៣១,៥% ចង់ទាមទារសំណងជំងឺចិត្តដែលជាការដាក់ទោសបន្ថែម ចំពោះអ្នកដែលជាប់ពិរុទ្ធ ច្រើនជាងប្រជាពលរដ្ឋនៅតំបន់ទីប្រជុំជនដែលមានត្រឹមតែ ១៧,២% ប៉ុណ្ណោះ ។

ប៉ុន្តែ ២២,១% នៃអ្នកឆ្លើយសំណួរ ចង់បានការសុំខមាលទោសដែលធ្វើឡើងដោយឧក្រិដ្ឋជនចំពោះការឈឺចាប់ពីអតីតកាល ។ ការសុំទោសជាសាធារណៈ ចំពោះអំពើសាហាវឃោរឃៅដែលបានប្រព្រឹត្តឡើងដោយគ្រាន់តែដើម្បីគោរពតាមបញ្ជា ឬដោយគ្រាន់តែបានដឹងអំពីអំពើឃោរឃៅនោះ នឹងមិនធ្វើឱ្យប្រជាពលរដ្ឋស្ទើរតែមួយភាគបួនដែលនៅរស់រានមាន ជីវិតរួចផុតពីរបបនោះ ស្ងប់ចិត្តបានឡើយ ។

## VI. អនុសាសន៍:

១. ការស្ទាបស្ទង់មតិរបស់វិទ្យាស្ថាន គឺជាការសង្កេតលើកទី៤ ដើម្បីសិក្សាពីទស្សនៈរបស់ប្រជាពលរដ្ឋខ្មែរអំពីតុលាការកាត់ទោសខ្មែរក្រហមដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខនេះ ។ ទោះបីយ៉ាងនេះក៏ដោយ ក៏នៅមិនទាន់គ្រប់គ្រាន់ដែរ ។ ការស្ទាបស្ទង់មតិទូទាំងប្រទេស ក៏នៅតែជាតំរូវការមួយដ៏ចាំបាច់ ហើយគួរតែត្រូវបានធ្វើឡើងឱ្យបានមុនតុលាការកាត់ទោសខ្មែរក្រហមត្រូវបានបង្កើតឡើង ដើម្បីឱ្យការរៀបចំផែនការបង្កើតឱ្យកាន់តែប្រសើរឡើង ។

២. នៅមានអ្នកឆ្លើយសំណួរចំនួន ២៤,៦% ទៀត ដែលមិនទាន់បានដឹងអំពីតុលាការកាត់ទោសខ្មែរក្រហម ។ ដោយដឹងថា ប្រជាពលរដ្ឋខ្មែរភាគច្រើន ទទួលព័ត៌មានតាមរយៈវិទ្យុ ឬទូរទស្សន៍ ហើយពុំសូវទទួលព័ត៌មានតាមរយៈកាសែត ឬសៀវភៅនោះទេ ។ រដ្ឋាភិបាលកម្ពុជា គួរចាប់ផ្តើមផ្សព្វផ្សាយ តាមរយៈវិទ្យុ និងទូរទស្សន៍ ដើម្បីបង្កើនការយល់ដឹងអំពីតុលាការនេះដល់ប្រជាពលរដ្ឋ ។ ប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាល នៅតែមិនទាន់បានទទួលព័ត៌មានគ្រប់គ្រាន់នៅឡើយ ។ អាស្រ័យហេតុនេះ យើងសូមផ្តល់យោបល់ដល់រដ្ឋាភិបាល ឱ្យបង្កើតនូវស្ថានីយ៍វិទ្យុតាមមូលដ្ឋាន នៅទូទាំងប្រទេស ក្នុងបំណងផ្សព្វផ្សាយព័ត៌មានអំពីប្រធានបទដ៏សំខាន់នោះប្រកបដោយប្រសិទ្ធិភាព ។

៣. វាជាការគួរឱ្យចាប់អារម្មណ៍ និងភ្ញាក់ផ្អើលណាស់ ដែលស្ត្រីបានដឹងអំពីតុលាការកាត់ទោសខ្មែរក្រហមនៅពេលខាងមុខនេះ តិចជាងបុរស ។ ក្នុងចំណោមស្ត្រីសរុប ២៣៧នាក់ ដែលត្រូវបានសម្ភាស មានតែ ៥៩,៥% ដែលបានដឹងអំពីតុលាការនេះ បើប្រៀបធៀបជាមួយបុរសចំនួន ៨៨,១% ក្នុងចំណោម ២៩៤នាក់ ។ សិទ្ធិរបស់ស្ត្រីក្នុងការទទួលព័ត៌មានមិនទាន់ត្រូវបានពង្រឹងការអនុវត្តន៍នៅឡើយ ។ វិទ្យុ និងបណ្ឌុបណ្តាលព័ត៌មានស្ត្រីជាក់លាក់មួយ និងកម្មវិធីពិភាក្សាតាមវិទ្យុសំរាប់ស្ត្រីគួរតែត្រូវបានបង្កើតឡើង ។ ដើម្បីលើកទឹកចិត្តឱ្យចូលរួមឱ្យបានច្រើនក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តផ្នែកនយោបាយ រដ្ឋាភិបាលកម្ពុជាគួរបង្កើតកិច្ចប្រឹងប្រែងរបស់ខ្លួនលើបញ្ហាសមភាពយេនឌ័រ ។

៤. ៤៤,១% នៃអ្នកផ្តល់ការសម្ភាសន៍ មិនចង់ឱ្យមានតុលាការ ជាជាងគ្រាន់តែមានតុលាការដែលមិនមានយុត្តិធម៌ ១០០% ។ តួលេខនេះ ចង្អុលបង្ហាញនូវកង្វះទំនុកចិត្តលើប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា ។ រដ្ឋាភិបាលត្រូវតែធានាឱ្យមាននូវនីតិវិធីតែងតាំងចៅក្រមខ្មែរដែលប្រកបដោយតម្លាភាព ហើយត្រូវតែកសាងទំនុកចិត្តថា ចៅក្រមដែលត្រូវបានតែងតាំងនៅពេលនោះមិនស្ថិតនៅក្រោមឥទ្ធិពលរបស់បុគ្គលណាមួយ និងដែលអាចបំពេញភារកិច្ចផ្លូវច្បាប់របស់ខ្លួនបានដោយឯករាជ្យ និងមិនលំអៀង ។

៥. ការស្ទាបស្ទង់មតិរបស់យើងបង្ហាញថា ៧១,២% នៃអ្នកឆ្លើយសំណួរ ព្រួយបារម្ភអំពីសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគាត់ នៅពេលដែលពួកគាត់ឡើងធ្វើជាកសិណសាក្សីនៅចំពោះមុខតុលាការកាត់ទោសខ្មែរក្រហម ។ សាក្សីម្នាក់ដែលត្រូវបានបំភិតបំភ័យ អាចធ្វើឱ្យប៉ះពាល់ដល់សាលក្រម និងធ្វើឱ្យខូចដល់លទ្ធផលនៃការជំនុំជំរះទាំងមូល ។ អាស្រ័យហេតុនេះ រដ្ឋាភិបាលគួរយកចិត្តទុកដាក់លើកម្មវិធីការពារសាក្សីដែលអាចទុកចិត្តបាន ដែលធានានូវសុវត្ថិភាពដល់សាក្សី។

៦. នៅពេលដែលតុលាការកាត់ទោសខ្មែរក្រហម កាន់តែខិតជិតចូលមកដល់ ប្រជាពលរដ្ឋកាន់តែនឹកឃើញច្រើនអំពីអតីតកាលដ៏សែនវេទនារបស់ពួកគាត់ ការប្រៀបធៀបលទ្ធផលនៃការស្ទាបស្ទង់មតិរបស់យើង ជាមួយនឹងលទ្ធផលនៃការស្ទាបស្ទង់មតិរបស់ "មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម" និង "មជ្ឈមណ្ឌលឯកសារកម្ពុជា" លាតត្រដាងនូវទំនាក់ទំនងដ៏ជិតដិតមួយរវាងតុលាការនាពេលខាងមុខ និងការចងចាំដែលមិនអាចបំភ្លេចបានរបស់ប្រជាពលរដ្ឋ ។ វាទំនងដូចជាថាប្រជាជនកាន់តែច្រើនឡើងៗនឹងទទួលរងនូវអារម្មណ៍នឹកឃើញពីអតីតកាល សុបិន្តអាក្រក់ ការថប់អារម្មណ៍ និងបញ្ហាចិត្តសាស្ត្រ ដទៃទៀត ។ ប្រការនេះ អាចនាំទៅរកការធ្លាក់ទឹកចិត្ត ភាពល្ងិតល្ងៃ និងសេចក្តីសោកសៅ ។

គួរឱ្យសោកស្តាយ ប្រទេសកម្ពុជាមានពេទ្យចិត្តសាស្ត្រដែលបានទទួលការបណ្តុះបណ្តាលតែ ២០នាក់ ប៉ុណ្ណោះដើម្បីដោះស្រាយនូវបញ្ហាប្រឈមនេះ ។ រដ្ឋាភិបាលគួរបង្កើតមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តទូទាំងប្រទេស ជាពិសេសនៅតំបន់ដាច់ស្រយាល ហើយគួរបង្កើននូវចំនួននៃអ្នកជំនាញសុខភាពផ្លូវចិត្ត ។ អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការក្នុងផ្នែកនេះគួរគាំទ្រដោយសប្បុរស ។ ព្រះសង្ឃ និងអាចារ្យ ក៏គួរចូលរួមចំណែកជួយផ្តល់ជំនួយផ្លូវចិត្តដល់អ្នកមានជំងឺផងដែរ ៕